# CAMBREW LTD

Part of the Carlsberg Group










# អាជីវកម្មប្រកបដោយអនុលោមភាព រក្សាកិត្តិស័ព្ទដ៏ល្អប្រពៃរបស់ក្រុមហ៊ុន និងឆ្លុះបញ្ចាំងពីការចូលរួមអភិវឌ្ឍសង្គម








យើងមានមោទកភាពដែលទទួលបានការទទួលស្គាល់ និងកោតសរសើរពី សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ចំពោះការចូលរួមចំណែករបស់ ខេមប៊្រូវ ក្នុងចំណូលសារពើពន្ធរបស់រាជរដ្ឋាភិបាល តាមរយៈការជាប់ជាសហគ្រាសបង់ពន្ធធំជាងគេលំដាប់ទី៨ ឆ្នាំ២០២២ និងទទួលបានវិញ្ញាបនបត្រអនុលោមភាពសារពើពន្ធប្រភេទមាស ពីអគ្គនាយកដ្ឋានពន្ធដារ។

នេះជាឆ្នាំទី២ជាប់គ្នាហើយ ដែល ខេមប៊្រូវ ទទួលវិញ្ញាបនបត្រនេះ បន្ទាប់ពីបានក្លាយជាក្រុមហ៊ុនបុត្រសម្ព័ន្ធមួយរបស់កាសស្បឺរ គ្រុប។

លិខិតទទួលស្គាល់ និងកោតសរសើររបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន ត្រូវបានប្រគល់ជូនខេមប៊្រូវ ដោយឯកឧត្តម គង់ វិបុល ប្រតិភូរាជរដ្ឋាភិបាល ទទួលបន្ទុកជាអគ្គនាយកនៃអគ្គនាយកដ្ឋានពន្ធដារ។ នៅក្នុងសារថ្លែងអំណរគុណនោះ សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន បានគូសបញ្ជាក់ថា ការបំពេញកាតព្វកិច្ចពន្ធរបស់ក្រុមហ៊ុន ខេមប៊្រូវ គឺជាការចូលរួមដែលមិនអាចខ្វះបានពីវិស័យឯកជន ដែលសម្តេច ចាត់ទុកជាដៃគូដ៏សំខាន់របស់រដ្ឋ និងជាកម្លាំងចលករសម្រាប់ការអភិវឌ្ឍ និងភាពរីកចម្រើននៃសេដ្ឋកិច្ច និងសង្គមជាតិកម្ពុជា។

ខេមប៊្រូវ ជឿជាក់ថា ដើម្បីអាចរួមចំណែកក្នុងកិច្ចអភិវឌ្ឍប្រទេស និងសេដ្ឋកិច្ចជាតិ ពីវិស័យឯកជន គឺការធ្វើប្រតិបត្តិការអាជីវកម្ម ទាំងក្នុងខ្សែសង្វាក់តម្លៃទាំងមូលប្រកបដោយអនុលោមភាព និងទំនួលខុសត្រូវខ្ពស់ ជាមួយនឹងឆន្ទៈចូលរួមចំណែកក្នុងការជួយឱ្យសង្គមកាន់តែប្រសើរ។

# ខេមប្រ៊ូវ ទទួលបានពាន ASIA COMMERCIAL AWARDS 2023




ក្រុមហ៊ុន ខេមប្រ៊ូវ បន្តសម្រេចបាននូវសមិទ្ធផលក៏ប្រសើរ នៅដើមឆ្នាំ២០២៣នេះ ដោយបានឈ្នះពានរង្វាន់ ASIA COMMERCIAL AWARDS 2023 សម្រាប់ពាណិជ្ជសញ្ញាចំនួន ២ របស់យើង គឺស្ទីង និងស្រាបៀរ អង្គរ។ សម្រាប់ពាណិជ្ជសញ្ញា ស្ទីង យើងទទួលបានពាន « Outstanding Activation & Campaign in Off-Trade» រីឯស្រាបៀរ អង្គរ ទទួលបានពាន « EXCEL AT BRAND EXPERIENCE» ដោយការប្រកាសជ័យលាភីនេះ ត្រូវបានធ្វើឡើងនៅថ្ងៃទី២២ ខែមីនា ឆ្នាំ២០២៣ ក្នុងកិច្ចប្រជុំពាណិជ្ជកម្មប្រចាំតំបន់អាស៊ី នៅទីក្រុងវៀងច័ន្ទ ប្រទេសឡាវ។

## OUTSTANDING ACTIVATION/ CAMPAIGN IN THE OFF-TRADE



## EXCEL AT BRAND EXPERIENCE




ពានរង្វាន់នេះ គឺជាមោទកភាពថ្មីមួយទៀតរបស់ ខេមប្រ៊ូវ ក្នុងនាមជាក្រុមហ៊ុនដែលមាន ប្រតិបត្តិការលើរោងចក្រផលិតស្រាបៀរដំបូងគេនៅកម្ពុជា និងជាក្រុមហ៊ុនផលិតស្រាបៀរដ៏ធំបំផុតមួយនៅតំបន់អាស៊ីអាគ្នេយ៍។ សមិទ្ធផលនេះ នឹងក្លាយជាកម្លាំងជំរុញយើងឱ្យបន្តប្រឹងប្រែងបង្កើនកិត្តិស័ព្ទដ៏ល្អប្រពៃ របស់ពាណិជ្ជសញ្ញាផលិតផលរបស់យើង នៅលើទីផ្សារ និងប្រែក្លាយជារប្បធម៌ជោគជ័យនៅលើទីផ្សារ។

# តួនាទីស្ត្រីក្នុងកិច្ចអភិវឌ្ឍ




ទិវាអន្តរជាតិនារី ៨ មីនា ជាថ្ងៃដ៏ពិសេសមួយដែលពិភពលោកប្រារព្ធឡើង ដើម្បីអបអរសាទរដល់សមិទ្ធផលរបស់ស្ត្រី។
ដើម្បីអបអរសាទរទិវាអន្តរជាតិនារី ឆ្នាំនេះ កាសស្ប៊ែរតំបន់អាស៊ី និងកាសស្ប៊ែរ គ្រុប បានរៀបចំវេទិកាពិភាក្សា និងចែករំលែកបទពិសោធន៍ចំនួន២ សម្រាប់សហសេវិករបស់កាសស្ប៊ែរទូទាំងពិភពលោក ក្រោមប្រធានបទ «៥ គន្លឹះបំផុសស្មារតីក្រុមការងារនៅកន្លែងការងារ» និង «រួមគ្នាលើកកម្ពស់សមធម៌»។
យើងទទួលស្គាល់ពីសារសំខាន់ នៃវត្តមានរបស់ស្ត្រីនៅកន្លែងធ្វើការ និងយល់ស្របទាំងស្រុងថា ពិពិធភាព សមធម៌ និងបរិយាបន្ន (DE&I) គឺជាគន្លឹះដ៏សំខាន់ក្នុងការជំរុញគំនិតច្នៃប្រឌិតនវានុវត្តន៍ និងរួមចំណែកដល់ភាពរីកចម្រើននៃអាជីវកម្ម ក៏ដូចជាសង្គមទាំងមូល។

ក្នុងឱកាសដ៏ពិសេសនេះ Vlad អគ្គនាយកគ្រប់គ្រងក្រុមហ៊ុន ខេមប្រ៊ូវ ក៏បានសរសេរសារលិខិតចូលរួមអបអរសាទរទិវាអន្តរជាតិនារី ជាមួយសហសេវិកទាំងអស់ ជាពិសេសដើម្បីសម្តែងការគោរពកោតសរសើរចំពោះការចូលរួមរបស់សហសេវិកជាស្ត្រីក្នុងការអភិវឌ្ឍអាជីវកម្ម និងសង្គមរបស់យើង។
ពិពិធភាព សមធម៌ និងបរិយាបន្ន (DE&I) ត្រូវបានដាក់បញ្ចូលទៅក្នុងយុទ្ធសាស្ត្រស្នូល នៃអាជីវកម្មរបស់ខេមប្រ៊ូវ។ Vlad បានមានប្រសាសន៍ថា៖ «យើងម្នាក់ៗនៅខេមប្រ៊ូវ មានតួនាទីសំខាន់ក្នុងការជំរុញ និងអនុវត្តពិពិធភាព សមធម៌ និងបរិយាបន្ន (DE&I) នៅក្នុងប្រតិបត្តិការការងារប្រចាំថ្ងៃ និងក្នុងសហគមន៍របស់យើង ឱ្យក្លាយជាទម្លាប់ និងបង្កើតជាវប្បធម៌ដែលគ្រប់គ្នាចង់បាន»។
សូមចូលរួមទះដៃអបអរសាទរដល់ស្ត្រីរបស់យើងដែលពួកគាត់តែងតែរឹងមាំ មានភាពធន់ មានការប្តេជ្ញា មានឆន្ទៈប្រកបដោយទឹកចិត្តមោះមុត។ ការណ៍នេះ យើងនឹងអាចបង្កើតអនាគតដ៏ប្រសើររួមគ្នា។



# ការបណ្តុះបណ្តាលសមត្ថភាពគ្រូបង្គោលខាងក្នុងដ៏មានប្រសិទ្ធភាព រួមចំណែកដល់ការរីកចម្រើនឥតឈប់ឈររបស់ក្រុមហ៊ុន







ខេមប្រ៊ូវ បានរៀបចំវគ្គបណ្តុះបណ្តាលគ្រូបង្គោលខាងក្នុងដល់សហសេវិកដែលជាអ្នកសម្របសម្រួល ឬអ្នកបណ្តុះបណ្តាលខាងក្នុងក្រុមហ៊ុន ដែលដឹកនាំដោយ អ្នកជំនាញមានបទពិសោធន៍យ៉ាងទូលំទូលាយ គឺ Lisa Low  នាយកគ្រប់គ្រងផ្នែកអភិវឌ្ឍសមត្ថភាពប្រចាំតំបន់អាស៊ី។

វគ្គបណ្តុះបណ្តាលនេះ ប្រព្រឹត្តទៅកាលពីថ្ងៃទី១៤ មីនា ក្នុងគោលបំណងបង្កើនសមត្ថភាពអ្នកសម្របសម្រួល ឬអ្នកបណ្តុះបណ្តាលខាងក្នុងក្នុងក្រុមហ៊ុន ឱ្យកាន់តែមានជំនាញ និងបទពិសោធន៍ទូលំទូលាយនៅក្នុងតួនាទីជាអ្នកបណ្តុះបណ្តាល ឬយកទៅបណ្តុះបណ្តាលក្រុមការងារបន្តប្រកបដោយប្រសិទ្ធភាព។

វគ្គបណ្តុះបណ្តាលដែលបានរៀបចំដោយផ្ទាល់នៅខេមប្រ៊ូវនេះ ក៏បានបំពាក់ប៉ននដល់សិក្ខាកាម អំពីជំនាញទំនាក់ទំនងឱ្យកាន់តែមានប្រសិទ្ធភាព ក៏ដូចជារបៀបនៃការផ្តល់បទបង្ហាញយ៉ាងណាឱ្យអ្នកចូលរួមបានយល់ពីកម្មវត្ថុ និងខ្លឹមសារដែលយើងចង់ឱ្យពួកគេស្វែងយល់។ លើសពីនេះ សិក្ខាកាម ក៏បានស្វែងយល់ពីរបៀបនៃការបង្កើនការចូលរួមរបស់អ្នកចូលរួមក្នុងវគ្គបណ្តុះបណ្តាល ឬសិក្ខាសាលាផងដែរ។

សម្រាប់ ខេមប្រ៊ូវ គ្រូបង្គោលខាងក្នុងក្រុមហ៊ុន ដែលពោរពេញដោយទេពកោសល្យ ពិតជាសំខាន់ណាស់ ព្រោះរួមចំណែកក្នុងការកសាងក្រុមការងារដែលមានការតាំងចិត្ត និងទំនួលខុសត្រូវខ្ពស់ក្នុងតួនាទី និងការប្រើប្រាស់ធនធានដែលលយើងមាន ប្រកបដោយស័ក្តិសិទ្ធភាព ដែលចូលរួមដល់ការរីកចម្រើនដោយចីរភាពនៅក្នុងក្រុមហ៊ុន។

# សិក្ខាសាលាអំពីកម្មវិធីអភិវឌ្ឍសមត្ថភាពយុវជនទើបបញ្ចប់ការសិក្សា (GRADUAT TRAINEE PROGRAM) នៅតាមគ្រឹះស្ថានសិក្សាគោលដៅ








ក្នុងនាមជាក្រុមហ៊ុនបុត្រសម្ព័ន្ធមួយរបស់ កាសស្បឺរ គ្រុប ខេមប្រ៊ូវ បានបន្តផ្តល់ឱកាសដល់យុវជន ដើម្បីអភិវឌ្ឍសមត្ថភាព ជំនាញ ទេពកោសល្យ និងអាចចាប់យកអាជីពការងារក្នុងក្តីស្រមៃរបស់ពួកគេ តាមរយៈកម្មវិធីអភិវឌ្ឍ សមត្ថភាពយុវជនដែលទើបបញ្ចប់ការសិក្សា (Graduate Trainee Program)។

កម្មវិធីនេះ កំពុងបើកជ្រើសរើសបេក្ខភាពជំនាន់ទី២ ចំនួន៥ រូប រហូតដល់ថ្ងៃទី១៥ ខែមេសា ដើម្បីដុសខាត់សមត្ថភាពរបស់ពួកគេ ក៏ដូចជាផ្តល់បទពិសោធន៍ការងារជាក់ស្តែងនៅក្នុងផ្នែកព័ត៌មានវិទ្យា ហិរញ្ញវត្ថុ ទីផ្សារ ផ្នែកលក់ និងផ្នែកខ្សែច្រវាក់ផ្គត់ផ្គង់ នៅខេមប្រ៊ូវ។

នៅក្នុងខែមីនា ខេមប្រ៊ូវ បានរៀបចំសិក្ខាសាលាអំពីកម្មវិធីនេះ ជូនដល់និស្សិត ដែលត្រៀមបញ្ចប់ការសិក្សានៅសាលា CamEd Business School និងសាកលវិទ្យាល័យអាមេកាំងភ្នំពេញ ។ បទបង្ហាញរបស់យើង ទទួលបានការចាប់អារម្មណ៍ជាខ្លាំងពីនិស្សិត ដោយមានការចូលរួមជាង១០០នាក់ ។








កម្មវិធីអភិវឌ្ឍសមត្ថភាពដ៏មានសារសំខាន់មួយនេះ មានរយៈពេល២ឆ្នាំ ដែលបង្កើតឡើងដោយ កាសស្បៀរ គ្រុប ក្នុងគោលបំណងផ្តល់ឱកាសដល់យុវជនទើបបញ្ចប់សិក្សា អាចអភិវឌ្ឍសមត្ថភាព ជំនាញ ទេពកោសល្យ បើកសក្តានុពលរបស់ខ្លួន ក៏ដូចជាដើម្បីអាចក្លាយជាអ្នកដឹកនាំនាពេលអនាគត។
ខេមប្រ៊ូវ រង់ចាំទទួលពាក្យរបស់យុវជនដែលពោរពេញដោយការតាំងចិត្តខ្ពស់ មានមហិច្ឆតាអភិវឌ្ឍខ្លួន មកក្រេបយកចំណេះដឹងបទពិសោធន៍ការងារ នៅក្នុងក្រុមហ៊ុនអន្តរជាតិដែលឈានមុខគេមួយ នៅកម្ពុជា។




# ខេមប្រ៊ូវ រក្សាភាពជាគំរូក្នុងប្រតិបត្តិការអាជីវកម្មដែលមានតម្លាភាព

ខេមប្រ៊ូវ រក្សានូវមហិច្ឆតាក្នុងភាពឈានមុខគេជានិច្ច ទាំងគុណភាព ស្តង់ដារផលិតផល និងភាពជាគំរូលើការអនុលោមតាមច្បាប់ និងបទប្បញ្ញត្តិនានា ដើម្បីធានាថាយើងបានធ្វើប្រតិបត្តិការអាជីវកម្មប្រកដោយវិជ្ជាជីវៈ មានក្រមសីលធម៌ខ្ពស់ និងមានតម្លាភាព ស្របតាមចក្ខុវិស័យចូលរួមអភិវឌ្ឍសង្គមឱ្យកាន់តែប្រសើរ។

សម្រាប់យើង ទង្វើស៊ីសំណូកសូកប៉ាន់គ្រប់ទម្រង់ គឺជាសកម្មភាពមួយដែលបង្ហាញពីភាពមិនស្មោះត្រង់ និងមិនអាចអត់ឱនឱ្យបាន ព្រោះនឹងធ្វើឱ្យកិត្តិយសក្រុមហ៊ុនអាប់ឱន ហើយអាចបង្កមហន្តរាយដល់អាជ្ញាបណ្ណអាជីវកម្មរបស់យើងថែមទៀតផង។

ដោយមើលឃើញពីភាពចាំបាច់ និងហានិភ័យប្រឈមទាំងនេះ ខេមប្រ៊ូវ បន្តខ្នះខ្នែងបណ្តុះបណ្តាលសហសេវិករបស់យើងគ្រប់រូប ឱ្យប្រកាន់ខ្ជាប់ខ្ជួននូវគោលការណ៍តម្លាភាព នៅក្នុងការអនុវត្តកិច្ចការងារប្រចាំថ្ងៃរបស់ពួកគេ។ យើង បានរៀបចំវគ្គបណ្តុះបណ្តាលស្តីពីការប្រឆាំងនឹងអំពើពុករលួយ និងការស៊ីសំណូក ដល់សហសេវិកដែលមានទំនាក់ទំនងការងារជាមួយមន្ត្រីរដ្ឋាភិបាល កាលពីថ្ងៃទី២២ ខែមីនា ឆ្នាំ២០២៣ រួមមានសហសេវិកមកពីផ្នែកធនធានមនុស្ស ទំនាក់ទំនងកិច្ចការសាជីវកម្ម លទ្ធកម្ម ដឹកជញ្ជូន ពន្ធដារ និងផ្នែកហិរញ្ញវត្ថុ។

## When are you most likely to deal with Government?

- Dealing with Government as Customer?
- Dealing with Government Officials based at Carlsberg sites?
- When obtaining authorisations, permits and licenses?
- Through Third parties dealing with Government on Carlsberg's behalf?

33

Carlsberg Group

វគ្គបណ្តុះបណ្តាលនេះ រៀបចំឡើងក្នុងគោលបំណងបង្កើនការយល់ដឹង ពាក់ព័ន្ធនឹងការធ្វើទំនាក់ទំនងជាមួយមន្ត្រីរាជរដ្ឋាភិបាល សកម្មភាពណាខ្លះដែលត្រូវធ្វើ និងសកម្មភាពដែលត្រូវបានហាមឃាត់  ក៏ដូចជាផ្តល់ដំណោះស្រាយ ឆ្លើយតបនឹងសំណើបង់ប្រាក់សម្របសម្រួលណាមួយជាដើម។
ជាការពិតណាស់ ការធ្វើទំនាក់ទំនងជាមួយមន្ត្រីរដ្ឋាភិបាល គឺជាសកម្មភាពដែលសហសេវិករបស់យើងមិនអាចចៀសផុតបាននោះឡើយ។ ប៉ុន្តែ ការប្រព្រឹត្តអំពើពុករលួយ ស៊ីសំណូកស៊ូកប៉ាន់ គឺ ជារឿងដែលយើងត្រូវតែចៀសវាងឱ្យបាន។ យើងចង់ឃើញសហសេវិករបស់យើង ដើរតួជាគំរូនាំមុខគេក្នុងការអនុវត្តនូវសកម្មភាពប្រយុទ្ធប្រឆាំងនឹងអំពើពុករលួយ និងស៊ីសំណូក។ ភាពជោគជ័យរបស់យើង គឺការកសាងកេរ្តិ៍ឈ្មោះ និងកិត្យានុភាពដ៏ល្អប្រពៃដល់ក្រុមហ៊ុន ដើម្បីចូលរួមអភិវឌ្ឍសង្គមឱ្យកាន់តែប្រសើរ។

# កម្មវិធីតម្រង់ទិសសហសេវិកថ្មីរបស់ខេមប្រ៊ូវ ពង្រឹងស្មារតីក្រុមការងារតែមួយ ឆ្ពោះទៅសម្រេចគោលដៅរួម




ក្រុមការងារដែលខ្លាំង ភាពចាំបាច់ណាស់ត្រូវ មានស្មារតីក្រុមតែមួយ ដឹងច្បាស់ពីគោលបំណង និងឈរលើគោលដៅតែមួយរួមគ្នា។

ដើម្បីឱ្យសហសេវិកទាំងអស់ មានស្មារតីការងាររួមគ្នាជាធ្លុងមួយ ហើយពួកគេបានយល់ដឹងច្បាស់អំពីចក្ខុវិស័យ និងមហិច្ឆតារបស់ក្រុមហ៊ុន ខេមប្រ៊ូវ បានបន្តរៀបចំកម្មវិធីតម្រង់ទិសដល់សហសេវិកដែលទើបចូលធ្វើការថ្មីទាំងអស់។ កម្មវិធីនេះ មានរយៈពេលមួយថ្ងៃពេញ ដែលរៀបចំឡើងជារៀងរាល់ខែ។

កម្មវិធីនេះ រៀបចំឡើងក្នុងគោលបំណង ដើម្បីផ្តល់ការស្វាគមន៍យ៉ាងកក់ក្តៅពីរៀមច្បងក្នុងក្រុមហ៊ុន ក៏ដូចជាផ្សារភ្ជាប់ និងបំផុសស្មារតីរបស់ពួកគេ ទៅនឹងចក្ខុវិស័យរបស់ក្រុមហ៊ុន ដើម្បីឆ្ពោះទៅសម្រេចគោលដៅរួមគ្នាតែមួយ។

តាមរយៈកម្មវិធីនេះ ទាំងសមត្ថភាព និងស្មារតី ត្រូវបានពង្រឹងបន្ថែម។ សមាជិកថ្មីរបស់យើង បានស្វែងយល់អំពីចក្ខុវិស័យ បេសកកម្ម យុទ្ធសាស្ត្រអាជីវកម្មអាទិភាព និងផែនការអាជីវកម្មរបស់យើង។ បន្ទាប់ពីកម្មវិធីនេះ ត្រូវបានផ្អាករយៈពេលពីរឆ្នាំដោយសារវិបត្តិកូវីដ-១៩ ការវិលត្រឡប់នៃកម្មវិធីនេះ បានមកជាមួយនឹងស្នាមញញឹមរបស់សមាជិកថ្មី ព្រោះថានេះ គឺជាទំព័រដំបូងរបស់ពួកគេ ក្នុងការរួមដំណើរជាមួយខេមប្រ៊ូវប្រកបដោយឆន្ទៈដ៏មោះមុត។

# ខេមប្រ៊ូវ ជំរុញនវានុវត្តន៍ក្នុងវិស័យផលិតភេសជ្ជៈ តាមរយៈការចូលរួមតាំងពិព័រណ៍វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ កម្ពុជា-អន្តរជាតិ លើកទី១ ឆ្នាំ២០២៣



ខេមប្រ៊ូវ ដែលជាក្រុមហ៊ុនផលិតស្រាបៀរធំជាងគេមួយនៅកម្ពុជា មានក្ដីសោមនស្សរីករាយជាខ្លាំង ដែលមានវត្តមានចូលរួមនៅក្នុងកម្មវិធីពិព័រណ៍វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ កម្ពុជា-អន្តរជាតិ លើកទី១ ឆ្នាំ២០២៣ ដែលរៀបចំឡើងនៅមជ្ឈមណ្ឌលសន្និសីទ និងពិព័រណ៍កោះពេជ្រ ចាប់ពីថ្ងៃទី២៦ ដល់ថ្ងៃទី២៨ ខែមីនា ឆ្នាំ២០២៣ ។

ពិព័រណ៍នេះ ត្រូវបានផ្ដួចផ្ដើមរៀបចំឡើងដោយក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ និងជាផ្នែកមួយនៃទិវាជាតិ «វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍» ដែលត្រូវបានរាជរដ្ឋាភិបាលកម្ពុជាសម្រេចឱ្យមានការរៀបចំឡើងជារៀងរាល់ឆ្នាំ ដោយចាប់ផ្ដើមពីឆ្នាំ២០២៣នេះតទៅ។






ខេមប្រ៊ូវ បានចូលរួមដាក់តាំងផលិតផល មានដូចជាស្រាបៀរ និងភេសជ្ជៈ ដែលផលិតឡើង ប្រកបដោយភាពច្នៃប្រឌិត និងគំនិតអភិវឌ្ឍន៍ថ្មីៗ ជាមួយនឹងបច្ចេកវិទ្យា និងបច្ចេកទេសផលិតដ៏ទំនើប។

ជាមួយនឹងបទពិសោធន៍នៃការធ្វើប្រតិបត្តិការអាជីវកម្ម អស់រយៈពេលជាច្រើនឆ្នាំ ទាំងនៅប្រទេសកម្ពុជា ក្នុងតំបន់ និងពិភពលោក យើងតែងអភិវឌ្ឍ និងច្នៃប្រឌិតផលិតផលរបស់យើង ស្របតាមតម្រូវការរបស់អតិថិជន មិនត្រឹមតែរសជាតិ និងគុណភាពខ្ពស់ តែក៏ស្របតាមស្តង់ដារអន្តរជាតិផងដែរ។

គុណភាពស្របតាមស្តង់ដារដ៏ខ្ពស់បំផុត និងមហិច្ឆតា គឺជារឿងដែលយើងត្រូវតែផ្តោតការយកចិត្តទុកដាក់ខ្លាំងបំផុត ដើម្បីធានាថា យើងនៅតែរក្សាការគាំទ្រ និងទទួលបានការជឿទុកចិត្តពីអតិថិជនរបស់យើង ក៏ដូចជាដើម្បីបន្តរក្សាភាពនាំមុខគេមួយនៅក្នុងទីផ្សារ។






# ស្ទីង នាំយកការប្រគំតន្ត្រីអាស៊ានដ៏រំភើបអស្ចារ្យ FFF ASEAN PARTY ដំបូងគេនៅកម្ពុជា




ស្ទីង និងកំពូលតារាចម្រៀងរ៉េប ជី ដេវីត បាននាំយកនូវភាពរំភើបរីករាយ និងការហោកញៀវជូនអ្នកគាំទ្រខ្លួន នៅដើមឆ្នាំ២០២៣នេះ ជាមួយនឹងការប្រគំតន្ត្រី អាស៊ានដ៏ធំអស្ចារ្យ FFF ASEAN PARTY ដំបូងគេនៅប្រទេសកម្ពុជា។

ការរៀបចំកាន់តែធំ កាន់តែពិសេសជាងមុន ឆាកតន្ត្រីដ៏ធំអស្ចារ្យ FFF ASEAN PARTY ដែលនាំមកជូនភេសជ្ជៈស្ទីងរបស់យើង ដោយ មានការចូលរួមសម្តែងពីកំពូលតារាចម្រៀងរ៉េបប្រចាំប្រទេសកម្ពុជា គឺលោក ជី ដេវីត និងសិល្បករសិល្បការិនីល្បីៗមកពី៤ប្រទេសផ្សេងទៀត ក្នុងតំបន់អាស៊ាន រួមមានថៃ ហ្វីលីពីន វៀតណាម និង ឥណ្ឌូណេស៊ី។

សហសេវិករបស់យើង ក៏បានអនុញ្ញាតឱ្យចូលរួមសប្បាយរីករាយក្នុងព្រឹត្តិការណ៍ប្រគំតន្ត្រីដ៏អស្ចារ្យមិនធ្លាប់មានពីមុននេះផងដែរ។

ក្នុងនាមជាពាណិជ្ជសញ្ញាដែលនាំថាមពល និងផ្តល់ភាពស្វាហាប់ ស្ទីងពិតជាមានមោទកភាពយ៉ាងក្រៃលែង ដែលបានចូលរួមចំណែកក្នុងការអភិវឌ្ឍវិស័យតន្ត្រីនៅប្រទេសកម្ពុជា និងបាននាំយកភាពសប្បាយរីករាយជូនអ្នកគាំទ្រ ក៏ដូចជាអ្នកនិយមស្រលាញ់តន្ត្រី។

គ្មានព្រឹត្តិការណ៍ដ៏អស្ចារ្យទាំងនោះទេ បើគ្មានការគាំទ្ររបស់អតិថិជនចំពោះភេសជ្ជៈស្ទីង។ តាមរយៈព្រឹត្តិការណ៍ទាំងនេះ នឹងជួយយើងពន្លឿនសន្ទុះនៃការគាំទ្រស្ទីង។ ហើយយើងសង្ឃឹមថា ស្ទីងនឹងអាចនាំយកទស្សនីយភាពថ្មី ប្លែក អស្ចារ្យ កក្រើក ជូនដល់អតិថិជនទូទាំងប្រទេសបន្ថែមទៀត។

# ស្តង់ចល័ត ប៊្លែក ផេនធ័រ ជំរុញការផ្សព្វផ្សាយ ពាណិជ្ជសញ្ញា និងអំពីគុណភាពស្រាបៀររសជាតិ មុតដិតឆ្ងាញ់ ដល់អតិថិជនទូទាំងប្រទេស




យុទ្ធនាការស្តង់ចល័ត ប៊្លែក ផេនធ័រ នៅតែបន្តសកម្មភាពរបស់ខ្លួន រហូតដល់ថ្ងៃទី១០ មេសា ដើម្បីជំរុញដល់ការលក់ ប៊្លែក ផេនធ័រ កំប៉ុងធំចំណុះ ៥០០ មល ដែលទើបតែដាក់លក់នៅលើទីផ្សារ និងផ្តល់នូវបទពិសោធន៍ថ្មីជូនដល់អតិថិជន។

ចាប់ផ្តើមតាំងពីថ្ងៃទី១០ ខែមីនា មក យុទ្ធនាការនេះចែកជា ៥ក្រុម និងបានធ្វើសកម្មភាពព្រមៗគ្នា នៅក្នុងតំបន់គោលដៅទាំង ៥ទូទាំងប្រទេស រួមមានភូមិភាគកណ្តាល ខាងជើង ខាងត្បូង ខាងលិច និងភូមិភាគខាងកើត។

ស្តង់ចល័ត ប៊្លែក ផេនធ័រ មិនត្រឹមតែផ្តល់ភាពងាយស្រួល និងមានភាពបត់បែនឆ្លើយតបនឹងតម្រូវការក្នុងសម័យទំនើបប៉ុណ្ណោះទេ ប៉ុន្តែក៏ត្រូវនឹងបរិបទ ព្រមទាំងចំណូលចិត្តរបស់អតិថិជនគោលដៅនៅតាមបណ្តាខេត្ត និងតាមតំបន់ជាយក្រុងផងដែរ ដោយហេតុថាស្តង់ចល័តត្រូវបានគេចាត់ទុកជាកន្លែង សម្រាកលំហែ និងការជួបជុំដ៏សាមញ្ញសម្រាប់ពេលវេលាខ្លី។ មិនត្រឹមតែប៉ុណ្ណោះ ក៏ជាកន្លែងទទួលទានដែលមានតម្លៃសមរម្យ ដើម្បីជួបជុំពិសាអាហារពេលល្ងាចជាមួយមិត្តភក្តិ និងក្រុមគ្រួសារ ហើយកន្លែងនោះហើយដែលមិនអាចគ្មានវត្តមានរបស់ ប៊្លែក ផេនធ័រ។

ចំណុចសំខាន់នៃយុទ្ធនាការស្តង់ចល័ត ប៊្លែក ផេនធ័រ  គឺផ្តោតសំខាន់លើការជំរុញការទទួលស្គាល់ និងគុណភាពផលិតផល។ យើងកំពុងតែកសាងទំនាក់ទំនងអតិថិជនជាមួយនឹងពាណិជ្ជសញ្ញាមួយនេះ ផ្តល់ចំណេះដឹងអំពីផលិតផល និងបង្កើតឱ្យមានការភ្ញាក់រលឹកសជាតិជាដើម។ នេះជាយុទ្ធសាស្រ្ត ដែល ឆ្លុះបញ្ចាំងពីការតភ្ជាប់គ្នា រវាងការងារនៅលើឌីជីថល និងលើទីផ្សារផ្ទាល់តែម្តង។
យើងជឿជាក់ថា យុទ្ធនាការនេះពិតជាចូលរួមធ្វើឱ្យពាណិជ្ជសញ្ញាមួយនេះ ទទួលបានការទទួលស្គាល់ និងគាំទ្រជាខ្លាំង។

# ពិសាគ្រឿងស្រវឹង
# សូមកុំបើកបរ!

No. 1881, Russian Boulevard, Phum Ta gnoun,
Sangkat Kakab, Khan Posenchey, Phnom Penh,
Kingdom of Cambodia

+855 (0) 16 880 695

info.kh@carlsberg.asia

Cambrew Ltd

Cambrewltd

Cambrew Ltd

Carlsberg Group
Carlsberg Cambodia